# សៀវភៅណែនាំ ការធ្វើជំរឿនឆ្នាំ2020 របស់អ្នកសម្រាប់សិស្សមណ្ឌលសិក្សាធិការ LAUSD និងឪពុកម្តាយ

## តើការធ្វើជំរឿននេះមានឥទ្ធិពលទៅលើសិស្ស LAUSD និងគ្រួសាររបស់ពួកគេយ៉ាងដូចម្តេច?

មណ្ឌលសិក្សាធិការរួបរួមរបស់រដ្ឋ Los Angeles (LAUSD) គឺជាសាលារៀនដែលធំជាងគេទីពីរនៅក្នុងប្រទេសដែលមានសិស្សថ្នាក់កុមារតូច ថ្នាក់កម្រិត K-12 កម្មវិធីអប់រំសម្រាប់មនុស្សពេញវ័យសរុបចំនួន 694,096 នាក់។ ជាការចាំបាច់បំផុតដែលត្រូវរាប់ចំនួនសិស្ស និងគ្រួសាររបស់ពួកគេដើម្បីធានាថាសាលាក្រុងនឹងទទួលបានការផ្តល់ឲ្យនូវមូលនិធិសហព័ន្ធសម្រាប់កម្មវិធីអប់រំសំខាន់ៗដូចជាកម្មវិធី Head Start ការអប់រំពិសេសមូលនិធិជំនួយជំពូក I ទៅដល់សាលារៀននៅក្នុងសហគមន៍ដែលមានប្រាក់ចំណូលទាប និងអាហារថ្ងៃត្រង់តាមសាលារៀន។

## តើខ្ញុំត្រូវឆ្លើយសំណួរស្ទង់មតិជំរឿននេះនៅពេលណា និងយ៉ាងដូចម្តេច?

នៅដើមឆ្នាំ2020 នឹងមានផ្តល់ជូនការជូនដំណឹងមួយទៅដល់លំនៅដ្ឋានរបស់អ្នកជាមួយនឹងការណែនាំអំពីរបៀបបំពេញការស្ទង់មតិជំរឿនតាមអនឡាញ។ ថ្ងៃធ្វើជំរឿនគឺនៅថ្ងៃទី1 ខែមេសា ឆ្នាំ2020។ អ្នកក៏អាចបំពេញការស្ទង់មតិនេះបានដោយការទូរសព្ទទៅកាន់ ខ្សែទូរសព្ទដោយឥតគិតថ្លៃ ដោយបំពេញការស្ទង់មតិលើក្រដាសដែលនឹងផ្ញើតាមប្រៃសណីយ៍ទៅលំនៅដ្ឋានរបស់អ្នក ប្រសិនបើអ្នកមិនឆ្លើយតបតាមអនឡាញទេ ឬក៏ត្រូវរងចាំអ្នកធ្វើជំរឿនចុះធ្វើជំរឿនដល់ផ្ទះរបស់អ្នកក៏បាន។ ប្រសិនបើអ្នកមិនមានអ៊ីនធឺណេតនៅផ្ទះទេ អ្នកអាចធ្វើដំណើរទៅកាន់បញ្ជរធ្វើជំរឿនរាប់រយកន្លែងនៅតាមសាលារៀន និងនៅទីតាំងផ្សេងទៀតទូទាំងទីក្រុង និងខោនធី Los Angeles។

## តើខ្ញុំអាចបំពេញការស្ទង់មតិនេះជាភាសាកំណើតរបស់ខ្ញុំបានដែរឬទេ?

ការស្ទង់មតិ (និងជម្រើសនៃការហៅទូរសព្ទដោយឥតគិតថ្លៃ) នឹងអាចប្រព្រឹត្តទៅបានតាមអនឡាញជាភាសាអង់គ្លេស និងភាសាចំនួន 12 ផ្សេងទៀត (អេស្ប៉ាញ វៀតណាម កូរ៉េ រុស្ស៊ី អារ៉ាប់ តាកាឡុក ប៉ូឡូញ បារាំង ក្រេអូលីហៃទី ព័រទុយហ្គាល់ និងជប៉ុន)។ ការស្ទង់មតិលើក្រដាស នឹងអាចប្រព្រឹត្តទៅបានជាភាសាអង់គ្លេសនិងអេស្ប៉ាញប៉ុណ្ណោះ។ ប៉ុន្តែ ក្រសួងជំរឿនសហរដ្ឋអាមេរិក នឹងមានសទ្ទានុក្រមភាសានានា និងសៀវភៅណែនាំដែលអាចស្វែងរកបានជាភាសាផ្សេងក្រៅពីភាសាអង់គ្លេសចំនួន 59 ភាសា។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមទៀតស្តីពីការធ្វើជំរឿនពីសាលារៀនរបស់កូនខ្ញុំបានដែរឬទេ?

នៅក្នុងឆ្នាំ2019 មណ្ឌលសិក្សាធិការ LAUSD និងផ្តល់សិក្ខាសាលាស្តីពីការធ្វើជំរឿនដល់គ្រួសារនានា ក្រៅពីយុទ្ធនាការរបស់ពួកគេឈ្មោះថា "យើងគឺជា LA រួបរួមតែមួយ (We Are One LA Unified)"៖ រួមគ្នាគាំទ្រដល់ក្រុមគ្រួសាររបស់ជនអន្តោប្រវេសន៍ LAUSD ក៏នឹងរួមបញ្ចូលនូវព័ត៌មានស្តីពីជំរឿនជាច្រើនភាសានៅក្នុងកម្មវិធីបច្ចុប្បន្នផ្សេងៗមួយចំនួនរបស់ពួកគេសម្រាប់ឪពុកម្តាយ និងសិស្សនិស្សិត។

ទីក្រុងLos Angeles និងផ្តល់ដំណោះស្រាយ(នានា) យ៉ាងសមស្រប ដើម្បីធានាការប្រើប្រាស់ដោយស្មើភាពគ្នានូវកម្មវិធី សេវាកម្ម និងមន្ទីរវេជ្ជស្ថានរបស់ខ្លួនសម្រាប់មនុស្សដែលមានពិការភាព។ ដើម្បីធ្វើការស្នើសុំ សូមទាក់ទងទៅនាយកដ្ឋានផ្នែកពិការភាពតាមរយៈ DOD.Contact@lacity.org ឬ (213) 202-5668 ជាមុន ក្នុងរយៈពេលប្រាំថ្ងៃធ្វើការឬលើសពីនេះ។

Eric Garcetti @MayorOfLA

census.lacity.org
#2020Census